

# រឿងអំពី ព្រះយេស៊ូវ



ដោយ លីនស៊ី ថេននើរ
ផ្អែកទៅលើដំណើររឿងពិត

ម៉ែ រំភើបចិត្តណាស់ ។ វាជាលើកដំបូងដែលនាងមកព្រះវិហារ ! ពួកអ្នកផ្សព្វផ្សាយសាសនាបានប្រាប់គ្រួសារនាងអំពីសាសនាចក្រនេះ ។ ពួកគេបានសម្រេចចិត្តមក ។

ម៉ែ បានក្រឡេកមើលជុំវិញខ្លួននាង ។ នាងបានឃើញក្រណាត់ពណ៌-សនៅលើតុ ។ មានអ្វីមួយនៅក្រោមក្រណាត់នោះ ។

« តើមានអ្វីនៅក្រោមក្រណាត់នោះ ? » ម៉ែ បានសួរអ្នកផ្សព្វផ្សាយសាសនា ។

ស៊ិស្ទើរ ហាន់សុន បានញញឹម ។ « វាគឺជាសាក្រាម៉ង់ » ។

*សាក្រាម៉ង់* ។ នោះគឺជាពាក្យមានន័យជ្រៅណាស់ ។ ម៉ែ បានស្ដាប់អ្នកផ្សព្វផ្សាយសាសនា ប្រាប់ម្ដាយ និង ឪពុកនាងអំពីវា ។ ប៉ុន្តែនាងពុំដឹងប្រាកដថា វាជាអ្វីនោះទេ ។

គ្រប់គ្នាបានច្រៀងចម្រៀង ។ បុរសពីនាក់បានលើកក្រណាត់សនោះឡើង ។ ថាសនំប៉័ងនៅក្រោមក្រណាត់នោះ ! ម៉ែ បានមើលពួកគេហែកនំប៉័ងនោះជាចំណិតតូចៗ ។

បន្ទាប់ពីច្រៀងចប់ បុរសម្នាក់បានអធិស្ឋាន ។ បុរសផ្សេងៗទៀតបានហុចនំប៉័ងនោះទៅឲ្យមនុស្សគ្រប់គ្នា ។

ស៊ិស្ទើរ ហ្គាសៀ ខ្សឹបថា « នំប៉័ងជួយយើងឲ្យចងចាំអំពីព្រះកាយរបស់ព្រះយេស៊ូវ ។

ម៉ែ បានចាប់យកចំណិតនំប៉័ង ។ នាងគិតក្នុងចិត្តថា ព្រះយេស៊ូវគង់នៅពីមុខនាង ។

ក្រោយមកមានការអធិស្ឋានមួយទៀត ។ បុរសទាំងនោះបានហុចថាស ដែលមានពែងទឹកតូចៗនៅក្នុងនោះ ។

ស៊ិស្ទើរ ហ្គាសៀ ខ្សឹបថា « ទឹកជួយយើងឲ្យចងចាំអំពីព្រះលោហិតរបស់ព្រះយេស៊ូវ ។ ទ្រង់បានសុគតដើម្បីយើង ដោយសារទ្រង់ស្រឡាញ់ពួកយើង » ។

ម៉ែ បានចាប់យកពែងទឹក ។ នាងបានគិតអំពីសេចក្ដីស្រឡាញ់ដ៏ខ្លាំងដែលព្រះយេស៊ូវមានចំពោះនាង ។ នាងមានអារម្មណ៍ថា ទ្រង់កំពុងឱបនាងយ៉ាងខ្លាំង ។

ក្រោយមក ស៊ិស្ទើរ ហាន់សុន បានឲ្យរូបភាពព្រះយេស៊ូវតូចមួយទៅ ម៉ែ ។ « យើងទទួលទាននំប៉័ង និង ទឹកដើម្បីចងចាំដល់ព្រះយេស៊ូវ និង ការសន្យាដើម្បីធ្វើតាមទ្រង់ » ។ នាងបានញញឹម ។ « តើប្អូនគិតយ៉ាងណាអំពីសាក្រាម៉ង់ ? »

ម៉ែ បានសម្លឹងមើលរូបភាពរបស់ព្រះយេស៊ូវ ។ នាងបានចាំពីអារម្មណ៍កក់ក្ដៅដែលនាងបានទទួល ។ នាងបានញញឹម ។ « វាអស្ចារ្យណាស់ ! ខ្ញុំស្រឡាញ់ព្រះយេស៊ូវ » ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ កាលីហ្វូញ៉ា ស.រ.អា. ។*

*រូបភាពរបស់ព្រះយេស៊ូវគ្រីស្ទ* ដោយ ហារី អែនឌើរសុន បានទទួលសិទ្ធិអនុញ្ញាតពីសារៈមន្ទីរប្រវត្តិសាសនាចក្រ រូបភាពដោយ ជេម ចនសុន